អ អ ក

EAC

**អាជ្ញាធរអគ្គិសនីកម្ពុជា**

លេខ ៥៤៨.៧៣.១៨ អអក

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ថ្ងៃ សុក្រ ៧ កើត ខែ បុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០១៨

# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

## ស្តីពីការពិគ្រោះយោបល់សាធារណៈលើគម្រោងបន្ថយអត្រាថ្លៃលក់អគ្គិសនីក្នុងតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា ចំនួន ១៧ រាជធានី-ខេត្ត មាននៅរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តព្រះសីហនុ ខេត្តតាកែវ ខេត្តកំពត ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តព្រៃវែង ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តព្រះវិហារ ខេត្តមណ្ឌលគិរី និងតំបន់ក្រៅទីរួមខេត្តរតនគិរី ដែលទទួលប្រភពអគ្គិសនីពីបណ្តាញជាតិ សម្រាប់ខួបនៃឆ្នាំ២០១៩

អាជ្ញាធរអគ្គិសនីកម្ពុជា សូមជម្រាបជូនសាធារណជន អ្នកប្រើប្រាស់អគ្គិសនី ដែលឋិតនៅក្នុងដែនអាជ្ញាបណ្ណចែកចាយរបស់អគ្គិសនីកម្ពុជា ចំនួន ១៧ រាជធានី-ខេត្ត មាននៅរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តព្រះសីហនុ ខេត្តតាកែវ ខេត្តកំពត ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តព្រៃវែង ខេត្តកំពង់ចាម នៅលើកោះពីរ ឃុំកោះពីរ ស្រុកក្រូចឆ្មារ និងនៅឃុំជាំក្រវៀន ឃុំជាំ និងផ្នែកខ្លះនៃឃុំចាន់មូល ស្រុកមេមត់ ខេត្តត្បូងឃ្មុំ និងទីរួមខេត្តត្បូងឃ្មុំ ផ្នែកខ្លះនៃស្រុកចិត្របុរី ស្រុកសំបូរ ស្រុកស្នួល និងក្រុងក្រចេះ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តព្រះវិហារ ស្រុកអូររាំង ស្រុកកោះញែក ស្រុកពេជ្រាដា និងក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី និងតំបន់ក្រៅទីរួមខេត្តរតនគិរី ដែលទទួលប្រភពអគ្គិសនីពីបណ្តាញជាតិ ឲ្យបានជ្រាបថា យោងតាមប្រកាសរបស់ក្រសួងរ៉ែ និងថាមពល លេខ០២៥៥. រថ.អវថ.ប្រក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលអត្រាថ្លៃលក់អគ្គិសនីឡើងវិញ នៅក្នុងផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី នៅព្រះរាជាណាចក្រកម្ពុជាសម្រាប់ការអនុវត្តបន្តពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២០ យោងតាមការពិនិត្យវិភាគថ្លៃអគ្គិសនីដែលបានធ្វើការគណនានៅក្នុងផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី ស្របតាមគោលការណ៍កំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា អនុក្រឹត្យស្តីពីគោលការណ៍វាយតម្លៃភាពត្រឹមត្រូវនៃចំណាយក្នុងអាជីវកម្មអគ្គិសនី និងបទប្បញ្ញត្តិ រួចមក អាជ្ញាធរអគ្គិសនីកម្ពុជាគ្រោងចេញសេចក្តីសម្រេចបន្ថយអត្រាថ្លៃលក់អគ្គិសនីរបស់អគ្គិសនីកម្ពុជា ចំនួន១៧ រាជធានី-ខេត្ត ដូចបានជម្រាបជូនខាងលើ តាមប្រភេទអតិថិជន និងអត្រាថ្លៃលក់អគ្គិសនី សម្រាប់ខួបឆ្នាំ ២០១៩ (លើវិក្កយបត្រចេញចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៩ ដល់ចុងខែមករា ឆ្នាំ២០២០) មានដូចខាងក្រោម៖

| ប្រភេទនៃអ្នកប្រើប្រាស់ និងលក្ខខណ្ឌនៃការទិញ | អត្រាថ្លៃបច្ចុប្បន្ន | អត្រាថ្លៃថ្មីឆ្នាំ២០១៩ |
|---|---|---|
| ១.អ្នកប្រើប្រាស់ប្រភេទលំនៅដ្ឋាន | | |
| អ្នកប្រើពី ១ ដល់ ១០ kWh ក្នុង ១ ខែ នៅរាជធានីភ្នំពេញ | ៦១០រៀល/kWh | ៣៨០រៀល/kWh |
| អ្នកប្រើពី ១ ដល់ ១០ kWh ក្នុង ១ ខែ នៅខេត្ត | ៤៨០រៀល/kWh | |
| អ្នកប្រើពី ១១ ដល់ ៥០ kWh ក្នុង ១ ខែ នៅរាជធានីភ្នំពេញ | ៦១០រៀល/kWh | ៤៨០រៀល/kWh |
| អ្នកប្រើពី ១១ ដល់ ៥០ kWh ក្នុង ១ ខែ នៅខេត្ត | ៦១០រៀល/kWh | |
| អ្នកប្រើពី ៥១ ដល់ ២០០ kWh ក្នុង ១ ខែ នៅរាជធានីភ្នំពេញ | ៧២០រៀល/kWh | ៦១០រៀល/kWh |
| អ្នកប្រើពី ៥១ ដល់ ២០០ kWh ក្នុង ១ ខែ នៅខេត្ត | ៧៧០រៀល/kWh | |
| អ្នកប្រើចាប់ពី ២០១ kWh ក្នុង ១ ខែ ឡើងទៅ នៅរាជធានីភ្នំពេញ | ៧៥០រៀល/kWh | ៧៤០រៀល/kWh |
| អ្នកប្រើចាប់ពី ២០១ kWh ក្នុង ១ ខែ ឡើងទៅ នៅខេត្ត | ៧៧០រៀល/kWh | |



**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
ទូរស័ព្ទ : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh

| | | |
|---|---|---|
| ២.អ្នកប្រើប្រាស់ធុនតូច ប្រភេទឧស្សាហកម្ម ពាណិជ្ជកម្ម និងរដ្ឋបាល | | |
| ធុនតូចដែលទិញពីខ្សែបណ្តាញចែកចាយសាធារណៈតាមតង់ស្យុងទាប នៅរាជធានីភ្នំពេញ | ៧៥០រៀល/kWh | ៧៤០រៀល/kWh |
| ធុនតូចដែលទិញពីខ្សែបណ្តាញចែកចាយសាធារណៈតាមតង់ស្យុងទាប នៅខេត្ត | ៧៧០រៀល/kWh | |
| ៣.អ្នកប្រើប្រាស់ធុនធំ និងធុនមធ្យម ប្រភេទឧស្សាហកម្ម | | |
| ធុនធំដែលទិញពីខ្សែបណ្តាញតង់ស្យុងមធ្យម តាមនាឡិកាស្ទង់ MV នៅរាជធានីភ្នំពេញ | 0.1650$US/kWh | 0.1470$US/kWh |
| ធុនធំដែលទិញពីខ្សែបណ្តាញតង់ស្យុងមធ្យម តាមនាឡិកាស្ទង់ MV នៅខេត្ត | 0.1640$US/kWh | |
| ធុនមធ្យមដែលទិញពីក្រោមត្រង់ស្វូផ្ទាល់ដែលត្រង់ស្វូវិនិយោគដោយអ្នកទិញ តាមនាឡិកាស្ទង់ LV ទាំងរាជធានីភ្នំពេញ និងខេត្ត | 0.1706$US/kWh | 0.1529$US/kWh |
| ធុនមធ្យមដែលទិញពីក្រោមត្រង់ស្វូផ្ទាល់ដែលត្រង់ស្វូវិនិយោគដោយអគ្គិសនីកម្ពុជា តាមនាឡិកាស្ទង់ LV ទាំងរាជធានីភ្នំពេញ និងខេត្ត | 0.1786$US/kWh | 0.1609$US/kWh |
| ៤.អ្នកប្រើប្រាស់ធុនធំ និងធុនមធ្យម ប្រភេទពាណិជ្ជកម្ម និងរដ្ឋបាល | | |
| ធុនធំដែលទិញពីខ្សែបណ្តាញតង់ស្យុងមធ្យម តាមនាឡិកាស្ទង់ MV នៅរាជធានីភ្នំពេញ | 0.1650$US/kWh | 0.1590$US/kWh |
| ធុនធំដែលទិញពីខ្សែបណ្តាញតង់ស្យុងមធ្យម តាមនាឡិកាស្ទង់ MV នៅខេត្ត | 0.1640$US/kWh | |
| ធុនមធ្យមដែលទិញពីក្រោមត្រង់ស្វូផ្ទាល់ដែលត្រង់ស្វូវិនិយោគដោយអ្នកទិញ តាមនាឡិកាស្ទង់ LV ទាំងរាជធានីភ្នំពេញ និងខេត្ត | 0.1706$US/kWh | 0.1654$US/kWh |
| ធុនមធ្យមដែលទិញពីក្រោមត្រង់ស្វូផ្ទាល់ដែលត្រង់ស្វូវិនិយោគ ដោយអគ្គិសនីកម្ពុជា តាមនាឡិកាស្ទង់ LV ទាំងរាជធានីភ្នំពេញ និងខេត្ត | 0.1786$US/kWh | 0.1734$US/kWh |
| ៥.អ្នកប្រើប្រាស់ប្រភេទអនុគ្រោះពិសេស | | |
| ការបូមទឹកធ្វើកសិកម្មពេលយប់ពី០៩យប់ ដល់០៧ព្រឹក | ៤៨០រៀល/kWh | ៤៨០រៀល/kWh |
| សាលារៀន មន្ទីរពេទ្យ មណ្ឌលសុខភាព នៅជនបទ | ៧៧០រៀល/kWh | ៦១០រៀល/kWh |

អនុវត្តតាមនីតិវិធីកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជាសូមដាក់ "ឯកសារបន្ថយអត្រាថ្លៃលក់អគ្គិសនី" ថ្មីនេះ ពិគ្រោះយោបល់ជាសាធារណៈ ជាមួយគ្រប់អ្នកពាក់ព័ន្ធទាំងអស់ មានក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន និងអ្នកប្រើប្រាស់អគ្គិសនី នៅក្នុងតំបន់ផ្គត់ផ្គង់អគ្គិសនីទាំង ១៧ រាជធានី-ខេត្ត របស់អគ្គិសនីកម្ពុជា ចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩ ។ ក្រោយថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩ "ឯកសារបន្ថយអត្រាថ្លៃលក់អគ្គិសនី" ថ្មីនេះនឹងត្រូវចាត់ទុកថាបានឆ្លងកាត់ការពិគ្រោះយោបល់រួច ហើយអាជ្ញាធរអគ្គិសនីកម្ពុជាអាចធ្វើការពិនិត្យ និងអនុម័តបញ្ជីថ្លៃលក់អគ្គិសនីថ្មីនេះទៅតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ។

ដើម្បីឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាអាចអនុវត្តការកំណត់បញ្ជីថ្លៃលក់អគ្គិសនី ស្របទៅតាមច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជាសំណូមពរសុំឲ្យការផ្តល់យោបល់មកឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាមានមូលដ្ឋានសំអាងគ្រប់គ្រាន់ ដើម្បីរក្សាបានយុត្តិធម៌រវាងផលប្រយោជន៍របស់អ្នកប្រើប្រាស់ផង និងអ្នកផ្គត់ផ្គង់ផង ។ ឯកសារបន្ថយអត្រាថ្លៃលក់អគ្គិសនី ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យលេខ ០៥៤.អនក្រ.បក មានតម្កល់ទុកនៅ អាជ្ញាធរអគ្គិសនីកម្ពុជា អគ្គិសនីកម្ពុជា សាខាអគ្គិសនីកម្ពុជាទៅតាមរាជធានី-ខេត្ត សាលារាជធានី-ខេត្តទាំង១៧ សម្រាប់អ្នកពាក់ព័ន្ធទាំងអស់ មានក្រសួង-ស្ថាប័ន រាជរដ្ឋាភិបាល អាជ្ញាធរមូលដ្ឋាន និងអ្នកប្រើប្រាស់ ដែលមានចំណាប់អារម្មណ៍ ពិនិត្យដោយសេរី នៅគ្រប់ពេលម៉ោងធ្វើការ ។

អាស្រ័យហេតុនេះ សូមអ្នកពាក់ព័ន្ធទាំងអស់ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ និងផ្តល់យោបល់ដល់អាជ្ញាធរអគ្គិសនីកម្ពុជា លើ "ឯកសារបន្ថយអត្រាថ្លៃលក់" ថ្មីនេះ មេត្តាជ្រាបជាព័ត៌មាន ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**
**ប្រធាន**

**ឃឹម ទិសិដ្ឋ**

**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
ទូរស័ព្ទ : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh